ជំពូកទី២៖ ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយនិងរបាយការណ៍ដែលត្រូវចងក្រង នឹងធ្វើឡើងដោយគោរពទៅតាម និងមានសុពលភាពក្របខ័ណ្ឌច្បាប់ និងអនុក្រឹត្យនានាដែលពាក់ព័ន្ធ ដែលមានបរិយាយដូចខាងក្រោមនេះ៖


២.១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ច្បាប់ស្តីអំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ហើយត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយ ព្រះរាជក្រមលេខ នស.រកម១២៩៦,៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ច្បាប់នេះមានគោលដៅ៖

- ការពារលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពប្រជាជនដោយធ្វើការទប់ស្កាត់ កាត់បន្ថយ និងការត្រួតពិនិត្យការបំពុល។
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញនូវសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលចំពោះគម្រោងដែលបានស្នើឡើង។
- ធានាឱ្យមានការអភិរក្សការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- បង្ក្រាបរាល់អំពើទាំងឡាយដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់នេះបានតម្រូវឱ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦ និងទី៧ នៃជំពូកទី៣ ដែលមានសេចក្តីដូចខាងក្រោម៖

<u>មាត្រា៦៖</u> ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ ការវាយតម្លៃនេះត្រូវអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុង



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ដំណើរការហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ ប្រភេទទំហំគម្រោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

<u>មាត្រា៧៖</u> ចំពោះពាក្យស្នើសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវត្រួតពិនិត្យ និងផ្តល់យោបល់លើ IEIA ឬ EIA ទៅអង្គភាពមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២.២ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

ច្បាប់ស្តីពីការពារធម្មជាតិ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំសភាលើកទី៧ នីតិកាលទី៣ ដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២។ មាត្រាសំខាន់ៗនៃច្បាប់នេះមានសេចក្តីដូចខាងក្រោម៖

<u>មាត្រា៤៖</u>

- ការគ្រប់គ្រងតំបន់ការពារធម្មជាតិដូចមានចែងនៅក្នុងមាត្រា២ នៃច្បាប់នេះត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។
- ក្រសួងបរិស្ថានមានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់ការពារធម្មជាតិនីមួយៗត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។
- ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋានជនជាតិភាគតិច និងសាធារណជនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តរភាព។

<u>មាត្រា៥៖</u>

រដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវបំពេញការកិច្ចសំខាន់ៗ ដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ។
- លើកការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ តាមតម្រូវការរបស់រាជរដ្ឋាភិបាល ឬអនុលោមទៅតាមអនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ។
- រៀបចំបទបញ្ញត្ត លិខិតបទដ្ឋាននានា ដើម្បីអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធិភាព។
- ចាត់វិធានការដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិ និងកសាងសំណុំបែបបទបញ្ជូនទៅតុលាការ។
- អប់រំផ្សព្វផ្សាយដល់សាធារណៈជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។
- រៀបចំកិច្ចព្រមព្រៀង ស្តីពីកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ។

<u>មាត្រា៦៖</u>

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានសិទ្ធិ និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- យោមល្បាត ត្រួតពិនិត្យ ជាប្រចាំ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ។
- ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗដែលកំណត់ដោយច្បាប់នេះ។
- មានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃ ក្នុងតំបន់ការពារធម្មជាតិ។
- ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាកក្នុងតំបន់ការពារធម្មជាតិ។
- ធ្វើការអប់រំផ្សព្វផ្សាយ និងសម្របសម្រួល ជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិចក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ។

<u>មាត្រា៨៖</u> ការសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណៈវិនិច្ឆ័យ គោលបំណងនៃការគ្រប់គ្រង សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធផ្សេងទៀត។

ការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវភ្ជាប់មកជាមួយនូវ៖

- ការអធិប្បាយអំពីសារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងការអភិរក្ស តំបន់ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិនោះ។
- ការអធិប្បាយអំពីលក្ខណៈច្បាប់ នៃតំបន់ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិភ្ជាប់ជាមួយនូវផែនទី មានមាត្រដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញយ៉ាងច្បាស់អំពី ទីតាំង ព្រំប្រទល់ និងទំហំនៃតំបន់ការពារធម្មជាតិនោះ។
- ការបញ្ជាក់ពីគោលបំណង នៃការគ្រប់គ្រងតំបន់ស្នើរៀបចំ និងការគម្រោងកំហែងចំពោះមុខ។
- ការសិក្សាលើការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លី នៅក្នុងតំបន់ការពារធម្មជាតិ។
- របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ ជាមួយស្ថាប័នភាគីពាក់ព័ន្ធ និងតំណាងអាជ្ញាធរមូលដ្ឋាន ដែលមានទីតាំងនៅក្នុង ឬក្បែរតំបន់ស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ។ ការរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៩៖</u>

រាជរដ្ឋាភិបាលអាចរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ដែលមានសារៈសំខាន់ចំពោះជាតិ និងអន្តរជាតិ ដើម្បីស្នើសុំចូលជាបេតិកភណ្ឌធម្មជាតិពិភពលោក ថ្នាក់តំបន់ ស្របតាមលក្ខណៈវិនិច្ឆ័យ អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងអន្តរជាតិថ្នាក់តំបន់។

តំបន់ការពារធម្មជាតិណាមួយ ដែលត្រូវបានចាត់បញ្ចូល ជាតំបន់បេតិកភណ្ឌធម្មជាតិពិភពលោក ឬបេតិកភណ្ឌធម្មជាតិថ្នាក់តំបន់រួចហើយ រាជរដ្ឋាភិបាលត្រូវមានវិធានការចាំបាច់ ដើម្បីធានានូវការគ្រប់គ្រងអភិរក្សតំបន់នេះ ដោយអនុលោមតាមសន្ធិសញ្ញា ឬអនុសញ្ញាបេតិកភណ្ឌធម្មជាតិថ្នាក់តំបន់។

តំបន់ការពារធនធានធម្មជាតិណាមួយ ដែលមានការទទួលស្គាល់ ដោយសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់អន្តរជាតិ ឬថ្នាក់តំបន់ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា១១៖</u>

តំបន់ការពារធម្មជាតិនីមួយៗ បែងចែកចេញជាបួន(៤) តំបន់គ្រប់គ្រង៖

១. តំបន់ស្នូល៖ ជាតំបន់គ្រប់គ្រង ដែលមានតម្លៃខ្ពស់ សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួល។

ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ។

២. តំបន់អនុរក្ស៖ ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ ការចេញ ចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុន ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចំបាច់ក្នុងវិស័យសន្តិសុខ និងការពារធម្មជាតិ។

ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។


៣. តំបន់ប្រើប្រាស់ដោយចីរភាព៖ ជាតំបន់គ្រប់គ្រង ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ បម្រើដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍន៍ និងការវិនិយោគនៅតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន។

៤. តំបន់សហគមន៍៖ ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់រួមមាន លំនៅដ្ឋានស្រែ និងចម្ការ។

ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

តំបន់ការពារធម្មជាតិនេះ មិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា១២៖</u>

ការបែងចែកតំបន់គ្រប់គ្រងទាំងបួនប្រភេទ ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- គោលបំណងនៃការគ្រប់គ្រងតំបន់
- តម្លៃមានសក្តានុពលធនធានធម្មជាតិ នៅក្នុងតំបន់នីមួយៗ
- សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលមិនប៉ះពាល់ទៅលើតំបន់នោះ
- លទ្ធភាព ទ្រទ្រង់នៃធនធានធម្មជាតិ
- ទីតាំងភូមិសាស្ត្រនៃតំបន់។

គោលការណ៍នៃការបែងចែកតំបន់គ្រប់គ្រងនីមួយៗ ក្នុងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

<u>មាត្រា១៣៖</u>

ការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រងបែងចែកនីមួយៗ ដូចមានចែងក្នុងមាត្រា១១ នៃច្បាប់នេះធ្វើទៅបានអាស្រ័យដោយ៖

- មានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់ និងប្រព័ន្ធអេកូឡូស៊ី រួមទាំងប្រភេទសត្វ រុក្ខជាតិធនធានជីវៈចម្រុះ សេនេទិច សេដ្ឋកិច្ចសង្គម និងវប្បធម៌ដែលមានការប្រែប្រួល ឬមានការគម្រាមកំហែង។
- អនុលោមតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

<u>មាត្រា១៤៖</u>

ក្រសួងបរិស្ថាន ត្រូវរៀបចំធ្វើផែនទីតំបន់ការពារធម្មជាតិនីមួយៗជាផ្លូវការ និងកំណត់លើផែនទីដែលមានមាត្រដ្ឋានច្បាស់លាស់ ដោយមានការចូលរួមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។

រដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវសិក្សារៀបចំបែងចែក និងកំណត់តំបន់គ្រប់គ្រងដូចមានចែងក្នុងមាត្រា១១ នៃច្បាប់នេះទៅតាមគោលការណ៍របស់ក្រសួងបរិស្ថាន និងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិនីមួយៗ ទៅតាមចំនុចដៅលើផែនទី ដែលនឹងកំណត់ដោយអនុក្រឹត្យ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា៣៤៖</u>

រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានសិទ្ធិចេញលិខិតអនុញ្ញាត កិច្ចព្រមព្រៀង ឬកិច្ចសន្យា ដែលពុំមានគោលដៅរកប្រាក់ចំណេញក្នុងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។

នីតិវិធីនៃការស្នើសុំ និងគម្រូបែបបទនៃលិខិតអនុញ្ញាត កិច្ចសន្យា ឬកិច្ចព្រមព្រៀងក្នុងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

<u>មាត្រា៣៦៖</u>

ការកាប់គាស់ការឈូសឆាយដីព្រៃក្នុងតំបន់ការពារធម្មជាតិ ដើម្បីស្ថាបនា និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់ប្រភេទដែលកាត់តាមតំបន់ស្នូល និងតំបន់អភិរក្ស ត្រូវហាមឃាត់។

ករណីនេះអាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមការស្នើរបស់ក្រសួងបរិស្ថាន។

<u>មាត្រា៣៧៖</u>

ការបោះ ឬការផ្ទេរទីតាំងឈរជើងអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នរបស់កងកម្លាំងប្រដាប់អាវុធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ធ្វើការសិក្សា លើការស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល។

ទីតាំងមូលដ្ឋានកងកម្លាំងប្រដាប់អាវុធដែលបាន និងកំពុងឈរជើងនៅក្នុងតំបន់ការពារធម្មជាតិហើយត្រូវរំសាយ ឬប្តូរទីតាំងទៅកន្លែងផ្សេងទៀតអង្គភាពកងកម្លាំងប្រដាប់អាវុធនេះ ត្រូវប្រគល់ទីតាំងទៅកន្លែងផ្សេងទៀត អង្គភាពកងកម្លាំងប្រដាប់អាវុធនេះ ត្រូវប្រគល់ទីតាំងមូលដ្ឋាននេះឱ្យមកក្រសួងបរិស្ថានគ្រប់គ្រង។

ហាមដាច់ខាតការធ្វើសមយុទ្ធ ការហ្វឹកហាត់ និងការបោះជម្រំកងកម្លាំងប្រដាប់អាវុធនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស នៃតំបន់ការពារធម្មជាតិ លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ សម្មភាពទាំងនេះ អាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដោយមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

<u>មាត្រា៣៨៖</u>

រាល់ការនាំចេញ ការនាំចូលគ្រាប់ពូជរុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្វព្រៃ និងពូជមច្ឆជាតិគ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិនិច្ឆ័យ វាយតម្លៃឱ្យបានច្បាស់លាស់ ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

<u>មាត្រា៣៩៖</u>

រាល់ការនាំចេញ ការនាំចូល ឬការដោះដូរ ដែលពុំមានលក្ខណៈពាណិជ្ជកម្ម នូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ ការបង្កាត់ពូជ និងសំណាករបស់ប្រភេទទាំងនេះប្រទេសដទៃត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិនិច្ឆ័យ និងវាយតម្លៃឱ្យបានច្បាស់លាស់ ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

<u>មាត្រា៤០៖</u>

ហាមបង្កឱ្យភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះបានចំពោះរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬអនាម័យព្រៃ។

ប្រជាជន កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់មានកាតព្វកិច្ចចូលរួមសហការក្នុងការថែរក្សា ការពារព្រៃឈើក្នុងការប្រយុទ្ធទប់ស្កាត់ភ្លើងឆេះព្រៃ។

ប្រជាជន កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់មានកាតព្វកិច្ចចូលរួមសហការក្នុងការថែរក្សាការពារព្រៃឈើក្នុងការប្រយុទ្ធទប់ស្កាត់ភ្លើងឆេះព្រៃ។

<u>មាត្រា៤១៖</u>

តំបន់ការពារធម្មជាតិនីមួយៗត្រូវការពារ និងទប់ស្កាត់នូវរាល់សកម្មភាពដែលធ្វើឱ្យខូចខាត ឬប៉ះពាល់អវិជ្ជមានក្នុងតំបន់ការពារធម្មជាតិបណ្តាលមកពីការកាប់គាស់រុករាន ទន្ទ្រានដីព្រៃដោយរំលោភ ការធ្វើអាជីវកម្ម ការបំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ការធ្វើកសិកម្មពនេចរ ការនាំចូលជម្ងឺសត្វល្អិតចង្រៃ និងប្រភេទរុក្ខជាតិ ឬសត្វរាតត្បាត។

សកម្មភាពដែលនាំឱ្យខូចខាត ឬប៉ះពាល់អវិជ្ជមាន ដែលត្រូវហាមឃាត់ក្នុងតំបន់ការពារធម្មជាតិមាន៖

- រំកិលដកចេញ ឬបំផ្លាញបង្គោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់គម្រោងការពារធម្មជាតិ។
- ប្រើសិទ្ធិប្រើប្រាស់ធនធានធម្មជាតិខុសពីសិទ្ធិដែលបានទទួលស្គាល់ ឬបានអនុញ្ញាតដោយច្បាប់។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- កាប់ ផ្តួលរំលំ គ្រៀវ កាប់បំផ្លាញដើមឈើ ឬបំពុល ឬគាស់រម្លើងគល់ឈើ។
- ការចាប់ប្រមាញ់ ប្រមូលពង កូនសត្វព្រៃ និងសត្វស្លាប តាមគ្រប់រូបភាព។
- ការបំផ្លាញគុណភាពទឹកតាមគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការសារធាតុគីមី ការចោលសំណល់រឹងរាវចូលក្នុងទឹក ឬលើដី ការប្រើប្រាស់ឧបករណ៍ឆក់។
- ការស្តុក ការទិញ និងការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទ។
- ការបំផ្លាញវាលស្មៅធម្មជាតិ រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ។
- ការលែងសត្វពាហនៈ និងបណ្តើរឆ្កែប្រមាញ់។
- ការនេសាទដែលផ្ទុយនឹងបទបញ្ញាត្តិនៃច្បាប់ ការធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹកព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ។
- ការបង្កើតមូលដ្ឋាន និងកែច្នៃខ្លឹមច័ន្ទន៍ ដើមម្រះព្រៅ វល្លិ៍រមៀត ឬអនុផលព្រៃឈើផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់ និងបច្ចេកទេស ដែលនាំដល់ការបំពុល ឬបំផ្លាញមជ្ឈដ្ឋានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

<u>មាត្រា៤២៖</u>

ហាមឃាត់ការកែច្នៃផល អនុផលធនធានធម្មជាតិ ការបង្កើត និងដំណើរការមូលដ្ឋានរោងអារ ជ្រៀកឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ។

<u>មាត្រា៤៣៖</u>

រូបវន្តបុគ្គល ឬនីតិបុគ្គលណាក៏ដោយ ពុំមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យរានដីព្រៃ កាន់កាប់ដី កាប់ដើមឈើ ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដែលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះ។

<u>មាត្រា៤៤៖</u>

ដើម្បីកាត់បន្ថយជាអតិបរមានូវប៉ះពាល់បរិស្ថាន និងសង្គម និងសម្រេច ឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោង អភិវឌ្ឍន៍ ឬវិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្រសួងបរិស្ថានត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុនដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់គម្រោង ឬសកម្មភាពណាមួយត្រូវអនុលោមតាមបទបញ្ញត្តទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

២.៣ ច្បាប់ស្តីពីព្រៃឈើ

ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៨០២/០១៦/៣១ អនុម័តនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៃគម្រោងវិនិយោគនេះមានដូចខាងក្រោម៖

<u>មាត្រា១៖</u>

- ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រងការប្រមូលផលការប្រើប្រាស់ ការធ្វើអាជីវកម្មការអភិវឌ្ឍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ដើម្បីផលប្រយោជន៍សង្គម-សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌។

<u>មាត្រា៣៖</u>

- ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹក ស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តទាំងឡាយ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត។
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្ត ដូចមានចែងនៅក្នុងជំពូកទី១៤ នៃច្បាប់នេះ។
- សកម្មភាពនេះ មិនធ្វើឱ្យប៉ះពាល់ដែលសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា៨៖</u>

- ក្នុងការអនុវត្តច្បាប់នេះ រាល់ការសម្រេចរបស់រដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។
- សកម្មភាពចម្បងៗ ដែលពាក់ព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានការប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងហេតុប៉ះពាល់សង្គម ដោយផ្អែកលើក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- ឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈរាល់ការសម្រេចចុងក្រោយ លើសកម្មភាពចម្បងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាល ត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ការសម្រេចចុងក្រោយណាមួយ ក្រោមមាត្រានេះរាជរដ្ឋាភិបាលអាចជូនដំណឹងជាសាធារណៈ។

<u>មាត្រា៧៖</u>

- សហគមន៍មូលដ្ឋានដែលប្រកបរបរចម្ការពនេរចរ មានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិច ដែលបានចុះបញ្ជីការរួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តចម្ការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។ ដីព្រៃឈើដែលរៀបចំសម្រាប់ចម្ការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៣៩៖</u>

- គ្មានរូបវន្តបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាតទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាន់កាប់ដីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះឡើយ។

<u>មាត្រា៩៨៖</u>

- បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតមានលក្ខខណ្ឌដូចដើមឡើងវិញ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

២.៤ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់នេះដាក់ឱ្យអនុវត្តដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១។ មាត្រាមួយចំនួនដែលពាក់ព័ន្ធនឹងគម្រោងអាចចែងដូចខាងក្រោម៖

<u>មាត្រា១</u>៖ ក្នុងច្បាប់បានចែងថា សេវាកម្មអគ្គិសនីក្នុងច្បាប់នេះសំដៅលើការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី ព្រមទាំងសេវាកម្មបន្ថែម ឬបន្ទាប់បន្សំភ្ជាប់ជាមួយសកម្មភាពទាំងនេះ។

<u>មាត្រា៣</u>៖ បានជម្រុញការរៀបចំ និងគ្រប់គ្រងនយោបាយយុទ្ធសាស្ត្រ និងផែនការរបស់ RGC លើវិស័យអគ្គិសនី ជាសមត្ថកិច្ចទទួលខុសត្រូវទូទៅរបស់ក្រសួងឧស្សាហកម្ម៉ែ និងថាមពល (MIME)។

- ការធានាឱ្យការផ្តល់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តិទៅដោយប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាព ជាសមត្ថភាពទទួលខុសត្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

<u>មាត្រា៨</u>៖ ចង្អុលបង្ហាញឱ្យឃើញថា អ្នកផ្គត់ផ្គង់សេវាកម្មអគ្គិសនីនីមួយៗ ត្រូវមានអាជ្ញាប័ណ្ណ ដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ហើយត្រូវអនុវត្តតាមបទបញ្ញត្តិនៃច្បាប់នេះ និងញត្តដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន ព្រមទាំងបទបញ្ញត្តិ និងនីតិវិធីរបស់អគ្គិសនីកម្ពុជា (EDC) និងការតម្រូវតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

- ពាល់ការសម្រេចចេញអាជ្ញាប័ណ្ណត្រូវផ្អែកលើគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការលើវិស័យអគ្គិសនីរបស់ RGC ដែលមានគោលបំណងកាត់បន្ថយចំណាយ ម៉ាហ្ស៊ីណាស់ រយៈពេលវែង និងខ្លីឱ្យបានតិចបំផុត ក្នុងការផ្គត់ផ្គង់អគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសេចក្តីសម្រេចនានាដូចមានចែងក្នុងមាត្រា៤។
- អាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ត្រូវធានាឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ប្រតិបត្តិតាមបទដ្ឋានទាក់ទងទៅនឹងកិច្ចប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន ដែលបង្កើតឡើង និងផ្សព្វផ្សាយដោយ MIME។

<u>មាត្រា៤២</u>៖ បានចែងថាអ្នកកាន់អាជ្ញាប័ណ្ណនិមួយៗ ត្រូវគោរពគ្រប់លក្ខខណ្ឌ ដែលមានចែង ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន បទបញ្ជា និងបទបញ្ញត្តទាំងអស់ដែល បានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាអាទិ៍បណ្តាច្បាប់ដែលពាក់ព័ន្ធ ដល់កិច្ចដំណើរការការពារបរិស្ថាន សុវត្ថិភាពពលកម្ម សុខភាព ពន្ធដារ និងអនុវត្តការការពារ និងស្តង់ដារនៃប្រព័ន្ធអគ្គិសនី។

<u>មាត្រា៦២</u>៖ បានកំណត់ថារាល់បទបញ្ញត្តការដោះស្រាយ និងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនី រួមទាំងការពន្យល់បកស្រាយជា លាយលក្ខណ៍អក្សរ ត្រូវដាក់ជូនបណ្តាភាគីដែលពាក់ព័ន្ធហើយត្រូវធ្វើឯកសារចម្លងជូនរាជរដ្ឋាភិបាល។

២.៥ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ នាថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

<u>មាត្រា១</u>៖ ច្បាប់នេះមានគោលដៅ ថែរក្សាការពារបេតិកភណ្ឌ វប្បធម៌ និងសម្បត្តិវប្បធម៌ ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធ ការនាំចេញ និងការនាំដោយខុសច្បាប់។

<u>មាត្រា២</u>៖ បេតិកភណ្ឌវប្បធម៌ជាតិគឺជាសម្បត្តិវប្បធម៌ ដែលត្រូវបានបង្កើតឡើង ឬក៏បានរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ។

<u>មាត្រា៣</u>៖ ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈ និងអចលនៈ ទៅជាកម្មសិទ្ធសាធារណៈ ក្តី ឬក៏ជាឯកជនក្តី ហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ។ លើកលែងតែមានបទបញ្ញត្ត ផ្ទុយពីច្បាប់នេះច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ។

<u>មាត្រា៤</u>៖ តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្ស និងរាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តអារ្យធម៌របស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះ បម្រើផលប្រយោជន៍សាធារណៈ។ សម្បត្តិវប្បធម៌ដែលបានរៀបរាប់ក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៥</u>៖ ការលើកគោលនយោបាយទូទៅ ក្នុងវិស័យសម្បត្តិវប្បធម៌ជាតិជាពិសេស ដើម្បីការពារ ថែរក្សា និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ ផ្នែកវប្បធម៌ជាតិ (ក.ជ.វ.ជ) ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាស្ថាប័នប្រតិបត្តិ។

ដោយឡែកនៅតំបន់សៀមរាបអង្គរ ការការពារថែរក្សា និងលើកតម្លៃបេតិកភណ្ឌ វប្បធម៌ជាតិត្រូវប្រគល់ឱ្យអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា អាជ្ញាធរអប្សរា។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ការសម្របសម្រួលភារកិច្ចរវាងក្រសួងវប្បធម៌ និងវិចិត្តសិល្បៈ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៦៖</u> រមណីយដ្ឋានដែលត្រូវការពាររួមមាន៖

- ឧទ្យានដែលមានបុរាណវត្ថុ ឬរមណីយដ្ឋានដទៃទៀត ដែលមានអត្ថប្រយោជន៍ សម្រាប់បុរាណវិទ្យា នរវិទ្យា ឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន។
- ព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើបស់ ក.ជ.វ.ជ។

<u>មាត្រា៧៖</u> ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ជូលនូវសម្បត្តិវប្បធម៌សាធារណៈ ឬឯកជនដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ទៅជាសម្បត្តិទាំងនោះមិនតម្រូវឱ្យចាត់ថ្នាក់ជាប្រញាប់ក៏ដោយ។

<u>មាត្រា៣៧៖</u> នៅពេលកំពុងដំណើរការងារផ្សេងៗ ឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ ដូចជាប្រាសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសម្បែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រ ដែលសិក្សាពីអតីតកាល ឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញ សម្បត្តិទាំងនេះ និងម្ចាស់អចលវត្ថុ ត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង។ អភិបាលខេត្ត ក្រុង ត្រូវជូនព័ត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌ និងរមណីយដ្ឋានវប្បធម៌នោះ។

២.៦ ច្បាប់ភូមិបាល

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២។ មាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងគម្រោងគឺមានសេចក្តីដូចខាងក្រោម៖

<u>មាត្រា១៖</u> ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា៣៖</u> ជនគ្រប់រូបត្រូវគោរពទ្រព្រសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែក រដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បទបញ្ជា និងនីតិវិធី នៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៧៖</u> របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់។

<u>មាត្រា៨៖</u> មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិលើដីនៅកម្ពុជា គឺប្រជាជនខ្មែរទាំងអស់ សមូហភាព ដែនដី សាធារណៈ គ្រឹះដ្ឋានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជាសហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬ ពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជា ដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។ ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឱ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោស ដូចចែង ក្នុងមាត្រា២៥១ នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះ ត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋ មិនចេញសំណងឱ្យឡើយ។

<u>មាត្រា១២៖</u> រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងក្នុងមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងទ្រព្យនិទាឃាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋ ដោយស្ម័គ្រចិត្ត ឬទ្រព្យ ដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬមិនមែនជាទ្រព្យ ដែលកំពុងកាន់កាប់ជារបស់ឯកជនស្របតាមបទបញ្ជាគ្តនៃជំពូកទី៤ នៃច្បាប់នេះ។

<u>មាត្រា១៤៖</u> រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ៖

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវា ឬក្បូន ចេញចូលបានបណ្តែត បឹងធម្មជាតិ ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបានបណ្តែតបាន និងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេស សម្រាប់ប្រយោជន៍ទូទៅ ដូចជាទីហានកំពង់ផែ ផ្លូវដែក ស្ថានីយ៍រថភ្លើង និងព្រលានយន្តហោះ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណី។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការ សម្រាប់សេវាសាធារណៈ ដូចជាសាលារៀន ឬអគារសិក្សា សាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់។
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។
- អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

<u>មាត្រា១៦</u>៖ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះ មិនអាចកំណត់អាយុកាលបានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចបិតនៅក្រោមការកាន់កាប់ដោយ លទ្ធកម្មពិសេសនៃជំពូកទី៤នៃច្បាប់នេះបានទេ។ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី៣នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធកណ្តាលជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនេះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុប្រយោគ។

<u>មាត្រា១៨</u>៖ ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយតកម្ម ទោះតាមរូបភាពណាក៏ដោយនូវ៖

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះ កើតឡើងនៅពេលណាក៏ដោយ ដែលមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក។
- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់នេះ ចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។
- រាល់សម្បទានមិនស្របនឹងបញ្ញត្តទាំងឡាយនៃជំពូកទី៥។

- ពាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន។

<u>មាត្រា៣០</u>៖ បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំយ៉ាងតិចគិតមកដល់ការបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្តាពរ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្តាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំនៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាង ដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ឬអ្នកទទួលផ្ទេរកម្មសិទ្ធិពីសន្តតិជនរបស់ខ្លួន។

<u>មាត្រា៣៣</u>៖ ក្នុងករណីមានការដកហូតអចលនវត្ថុដោយហឹង្សា ឬដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយប្រសិនបើគ្មានបណ្តឹងទាមទារពីភាគី ស្របច្បាប់នៃអចលនវត្ថុ ដែលត្រូវបានដកហូត។ បណ្តឹងទាមទារនេះមានរយៈពេល០៣ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត។

<u>មាត្រា៣៤</u>៖ អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណ ក្រោយច្បាប់នេះចូលជាធរមានត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា២៥៩ នៃច្បាប់នេះ។

<u>មាត្រា៣៥</u>៖ មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឱ្យអ្នកកាន់កាប់អចលនវត្ថុ គ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ។ សាមញ្ញជន ឬ អាជ្ញាធរដែលមិនតាងនាម រដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាព មានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ។ ការដេញអាចធ្វើបានតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ។ តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឱ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គល ដែលបង្ហាញប័ណ្ណត្រឹមត្រូវ និងពេញលេញរបស់ស៊ុរិយោដីបានឡើយ។

<u>មាត្រា៣៩</u>៖ ក្នុងការរង់ចាំដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់នេះ បង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ។ ភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួយ។

<u>មាត្រា៤២</u>៖ បុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួនដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និង មាត្រា៣១ នៃច្បាប់នេះ។

<u>មាត្រា៤៨</u>៖ ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ច មិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុ នោះអាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

<u>មាត្រា៤៧</u>៖ វិវាទរវាងភាគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេត និងដោះស្រាយតាមនីតិវិធីកំណត់។ លទ្ធផលនៃការស៊ើបអង្កេតត្រូវដាក់ជូនគណៈកម្មាការសុរិយោដីដែលបង្កើតឡើង នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មាការនេះត្រូវធ្វើសេចក្តីសម្រេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះដោយអនុក្រឹត្យ។

<u>មាត្រា៦៦</u>៖ បុគ្គលដែលមានសញ្ជាតិខ្មែរ និងមានសមត្ថភាពចុះកិច្ចសន្យាអាចលក់ ឬទិញទ្រព្យជាអចលនវត្ថុបាន។ បុគ្គលដែលមិនអាចលក់បានគឺ៖

- បុគ្គលដែលមិនមែនជាកម្មសិទ្ធិករនៃទ្រព្យដែលត្រូវលក់
- កម្មសិទ្ធិករនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករអវិភាគផ្សេងទៀត
- បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស។

បុគ្គលដែលមិនអាចទិញបានគឺ៖

- អាណាព្យាបាលមិនអាចទិញទ្រព្យរបស់បាលិតខ្លួន
- ហិតូបត្តម្ភកៈមិនអាចទិញទ្រព្យដែលខ្លួនគ្រប់គ្រង
- ចៅក្រម ឬភ្នាក់ងាររដ្ឋបាលមិនអាចទិញទ្រព្យដែលយុត្តាធិការរបស់ខ្លួន ឬដែលខ្លួនមានបេសកម្មលក់
- បុគ្គលដែលមានទ្រព្យត្រូវរឹបអូសមិនអាចទិញទ្រព្យនោះវិញបានទេ។

<u>មាត្រា៨៦</u>៖ កម្មសិទ្ធិករនៃទ្រព្យមិនអាចប្រើប្រាស់ទ្រព្យនោះក្នុងគោលដៅព្យាបាទ ឬរំខានដល់តតិយជន និងជាពិសេសដល់ អ្នកជិតខាងរបស់ខ្លួនបានឡើយ។ ការប្រើប្រាស់ទ្រព្យជាធម្មតាដែលមានចរិកធម្មានុរូបមិនអាចចាត់ទុកជាការរំខាន ដែលបណ្តាលឱ្យរាំងស្ទះដល់ការប្រើប្រាស់ទ្រព្យនោះបានឡើយ។

<u>មាត្រា៨៧</u>៖ កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដី រាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួនលើកលែងតែមានច្បាប់ហាមឃាត់។ ការរៀបចំ ឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ ស្របតាមបញ្ញត្តនៃផ្នែកទី៣ នៃជំពូកនេះ។

<u>មាត្រា១០៨</u>៖ បែបបទសំណង់ និងលក្ខខណ្ឌទាំងឡាយនៃការរៀបចំដែនដី និងនគរូបនីយកម្មចំពោះកម្មសិទ្ធិករ នឹងកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៧៨</u>៖ សហកម្មសិទ្ធិ គឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់ បែងចែកតាមឡូត៍ ដែលម្នាក់ៗបានមួយចំណែកជាឯកជន ហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម។

<u>មាត្រា៧៦</u>៖ សហកម្មសិទ្ធិករទាំងឡាយ អាចរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រង និងវិធានការនៃការថែទាំព្រមទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ជាពិសេសចំពោះផ្នែករួមដោយគោរពតាមបទបញ្ញត្តទាំងឡាយនៃច្បាប់នេះ។ ក្នុងករណីដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះទេសហកម្មសិទ្ធិត្រូវស្ថិតនៅក្រោមបទបញ្ញត្តទាំងឡាយដែលបានកំណត់ពីមាត្រា ១៧៧ ដល់មាត្រា១៨៥ នៃច្បាប់នេះ។

<u>មាត្រា៧៩</u>៖ រាល់ចំណែកនៃអាគារ ឬដីសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងឡាយ ឬសហកម្មសិទ្ធិករ ខ្លះក្នុងចំណោមនោះបង្កើតបានជាចំណែករួម។ ទ្រព្យរួមមានជាអាទិ៍៖

- ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល
- ជញ្ជាំងសសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្តាញទឹក ភ្លើង បណ្តាញ ឧស្ម័នដែលអាច ឆ្លងកាត់ចំណែកឯកជន
- ទ្រូម បំពង់ និងក្បាលបំពង់ផ្សែង
- ទីកន្លែងនៃសេវារួម។

សិទ្ធិបន្តបន្ទាប់ខាងក្រោមនេះក៏ត្រូវទុកជាកម្មសិទ្ធិរួមដែរ៖

- សិទ្ធិជីករុករកវត្ថុធាតុដែលមានក្នុងដី
- សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យានឬសួនច្បារដែលជាចំណែករួម
- សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យានឬសួនច្បារទាំងនេះ
- សិទ្ធិនៃអឌ្ឍសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ
- សិទ្ធិលើកបន្តឱ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើន បង្កើតបានជាចំណែកឯកជនផ្សេងគ្នា។ គ្មានករណីណាមួយដែលកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុត អាចលើកបន្តសម្រាប់តែខ្លួនឯងផ្តាល់ ឬលក់សិទ្ធិនៃការលើកនេះឡើយ។

- បទបញ្ញត្តនេះមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ។

<u>មាត្រា២៤៤</u>៖ អាជ្ញាធរមានសមត្ថកិច្ច អាចដាក់វិធានការឱ្យសហកម្មសិទ្ធិករ រ៉ាប់រងការថែទាំឱ្យល្អលើចំណែករួម។ សោហ៊ុយនៃការថែទាំជាបន្ទុកនៃសហកម្មសិទ្ធករ ដោយគិតតាមសមាមាត្រទៅនឹងតម្លៃនៃចំណែករៀងៗខ្លួន។ សហកម្មសិទ្ធិករដែលមិនព្រមរួមទទួលបន្ទុកនេះ ឬមិនគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា២៥៨ នៃច្បាប់នេះ។

<u>មាត្រា២៤៨</u>៖ ត្រូវចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុជាបទល្មើសព្រហ្មទណ្ឌក្នុងន័យ នៃច្បាប់នេះមាន៖

- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រំលោភកាន់កាប់អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី។
- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រារាំងអ្នកកាន់កាប់ដោយសន្តិភាព ឬកាគីនៃទ្រព្យមួយនៅក្នុងតំបន់មិនទាន់មានប្លង់សុរិយោដី ដែលរបបកម្មសិទ្ធិមិនទាន់បានពង្រឹងជាស្ថាពរ តាមបញ្ញត្តនៃច្បាប់នេះ។
- រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ ឬមិនប្រក្រតីលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនស្របតាមមាត្រា ១៧ មាត្រា១៨ និងមាត្រា១៩ នៃច្បាប់នេះ។
- រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម។

<u>មាត្រា២៤៩</u>៖ ការប៉ះពាល់កម្មសិទ្ធិក្នុងន័យនៃមាត្រាខាងលើ អាចជាទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬទង្វើរបស់សាមញ្ញជន ដែលធ្វើដោយម្នាក់ឯង ឬដោយផ្សំគំនិតជាមួយភ្នាក់ងាររបស់អាជ្ញាធរ។

<u>មាត្រា២៥០</u>៖ មន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ច ដែលបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើអចលនវត្ថុត្រូវទទួលទោសរដ្ឋបាល បន្ថែមលើទោសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី។

<u>មាត្រា២៥១</u>៖ ជនណាដែលបានក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយ ត្រូវផ្តន្ទាទោសដាក់ព័ន្ធនាគារពី ០១ (មួយ) ឆ្នាំ ដល់ ០៥ (ប្រាំ) ឆ្នាំ។

<u>មាត្រា២៥៣</u>៖ ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុច្ចរិត ទោះជាមិនទាន់ធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១.៥០០.០០០(មួយលានប្រាំសែន) រៀលដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល ឬដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់២ (ពីរ) ឆ្នាំដោយពុំទាន់គិតបញ្ចូលនូវទោស ប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្ស។ បន្ថែមលើទោសខាងលើ

អ្នកប្រព្រឹត្តអំពើហឹង្សាត្រូវទទួលខុសត្រូវចំពោះ សំណងរដ្ឋប្បវេណីដល់ជនរងគ្រោះដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន។ បើអំពើហិង្សាខាងលើត្រូវបញ្ជាពីជនដទៃទៀតក្រៅពីអ្នកបង្ក ហើយជននោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានោះក៏ត្រូវទទួលការផ្តន្ទាទោសដូចអ្នកប្រព្រឹត្តអំពើហិង្សាផ្ទាល់ដែរ។

<u>មាត្រា២៨៨៖</u> សហកម្មសិទ្ធិករ ដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម នៃសហកម្មសិទ្ធិខ្លួន ឬ មិនគោរពតាមលក្ខខណ្ឌ នៃសណ្តាប់ធ្នាប់សាធារណៈដូចមានចែងនៅក្នុងមាត្រា១៨៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន)ដល់ ៣.០០០.០០០ (បីលាន)រៀល។

<u>មាត្រា២៦១៖</u> មន្ត្រី ឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ជាក្តី ឬគ្មានបញ្ជាក្តីដើម្បីដកហូតអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០ (ដប់លាន) រៀល ដល់ ២៥.០០០.០០០(ម្ភៃប្រាំលាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។ ចាត់ទុកជាការរំលោភ មានការក្លែងបន្លំ ការកសាងប័ណ្ណដោយបំពានការកៀបសង្កត់ ឬវិធានការសម្ភារៈ ដើម្បីបណ្តេញចេញធ្វើឡើង ចំពោះអ្នកកាន់កាប់អចលនវត្ថុ។ បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សាចារីត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់២ (ពីរ) ឆ្នាំថែមទៀត។ អ្នកបញ្ជាដោយរំលោភត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តផ្ទាល់ដែរ។

<u>មាត្រា២៦៣៖</u> អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិកររបស់ភាគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន)រៀលដល់ ១០.០០០.០០០(ដប់លាន)រៀល នឹងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

២.៧ ច្បាប់ការងារ

ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានន័យសេចក្តីពាក់ព័ន្ធទៅនឹងគម្រោងមានបង្ហាញដូចខាងក្រោម៖

<u>មាត្រា១៖</u> ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនង ដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មការនិយោជិក ដើម្បីយកមកអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះមានសញ្ជាតិជាអ្វីហើយស្នាក់នៅទីណាក៏ដោយ។ ច្បាប់នេះអនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថានឧស្សាហកម្ម ពាណិជ្ជកម្ម សិប្បកម្ម សេវាកម្មដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹកទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅ



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

សាសនា ឬក្នុងសាសនាក៍ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៍ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬក្រុមប្រភេទណាក៍ដោយ។

<u>មាត្រា៣</u>៖ កម្មករនិយោជិកតាមន័យនៃច្បាប់នេះគឺ ជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃ ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬនីតិបុគ្គល ជាសាធារណៈ ឬឯកជន។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីលក្ខន្តិកៈ គតិយុត្តិនៃកម្មករនិយោជិកព្រមទាំងមិនត្រូវ គិតពីចំនួនប្រាក់ឈ្នួលតិច ឬច្រើនទេ។

<u>មាត្រា៤</u>៖ និយោជិក ឬអ្នកជួយ គឺជនដែលមានកិច្ចសន្យាជួយធ្វើការបុគ្គលណាម្នាក់ដោយយកកម្រៃ ប៉ុន្តែគ្មានធ្វើហត្ថកម្មពេញទី ឬក៍គ្រាន់តែជួយធ្វើហត្ថកម្មជាបន្ទាប់បន្សំប៉ុណ្ណោះ។

<u>មាត្រា៦</u>៖ កម្មករ គឺជាអ្នកធ្វើការយកឈ្នួល ក្រៅពីអ្នកបម្រើនៅក្នុងផ្ទះ និងនិយោជិក ពោលគឺជនដែលធ្វើការភាគច្រើន ខាងហត្ថកម្មយកកម្រៃក្រោមការដឹកនាំនៃនិយោជក ឬតំណាងនៃជននេះ។

<u>មាត្រា១១</u>៖ តាមរបៀបបើកប្រាក់ឈ្នួល កម្មកនិយោជិកត្រូវបែងចែកដូចតទៅនេះ៖

- កម្មកនិយោជិក ធ្វើការយកប្រាក់ឈ្នួលតាមពេល "ប្រចាំខែ ប្រចាំថ្ងៃ ប្រចាំម៉ោង" ដែលគេត្រូវបើកប្រាក់ឈ្នួលឱ្យរាល់ថ្ងៃ ឬរាប់ពេលមិនហួសពីដប់ថ្ងៃ ឬមួយខែ
- កម្មកនិយោជិក ធ្វើការយកប្រាក់ឈ្នួលតាមបរិមាណផលិតផល ឬមៅការ
- កម្មកនិយោជិក ធ្វើការយកកម្រៃជើងសា។

<u>មាត្រា១៤</u>៖ និយោជកត្រូវតែមានច្បាប់ការងារយ៉ាងហោចណាស់ មួយច្បាប់សម្រាប់សេចក្តីត្រូវការនៃកម្មករនិយោជិករបស់ខ្លួន ហើយជាពិសេសសម្រាប់តំណាងនៃកម្មករនិយោជិក នៅគ្រប់សហគ្រាសគ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់នេះ។

<u>មាត្រា១៨</u>៖ ការងារដោយបង្ខំ ឬជាកាតព្វកិច្ច ត្រូវហាមឃាត់ជាដាច់ខាត ដោយអនុលោមតាមអនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឬដោយកាតព្វកិច្ច អនុម័តនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣០ ដោយអង្គការការងារអន្តរជាតិ ហើយព្រះរាជាណាចក្រកម្ពុជា បានឱ្យសច្ចាប័ននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩។ មាត្រានេះត្រូវអនុវត្តលើបុគ្គលទាំងអស់ គិតទាំងអ្នកបម្រើក្នុងផ្ទះហើយនិងកម្មករនិយោជិកក្នុងសហគ្រាស កសិដ្ឋានទាំងឡាយ។

<u>មាត្រា១៦</u>៖ ការជួលមនុស្សឱ្យធ្វើការងារ ដើម្បីកាត់ជំពាក់ត្រូវហាមឃាត់។

<u>មាត្រា១៧</u>៖ និយោជកទាំងអស់ដែលត្រូវអនុវត្តច្បាប់ការងារនេះ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារ នៅពេលបើកសហគ្រាសគ្រឹះស្ថាន។ សេចក្តីប្រកាសជូនដំណឹងនេះហៅថា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ដែលត្រូវធ្វើជាលាយលក្ខណ៍



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

អក្សរ និងដាក់ជូនក្រសួងទទួលបន្ទុកវិស័យការងារ នៅមុនពេលបើកសហគ្រាសគ្រឹះស្ថានជាស្ថាពរ។

<u>មាត្រា១៨</u>៖ ចំពោះការបិទសហគ្រាស និយោជកក៏ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារដែរ ក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីថ្ងៃបិទសហគ្រាសនោះ។

<u>មាត្រា១៩</u>៖ ប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ កំណត់អំពីបែបបទ និងនីតិវិធីនៃការធ្វើសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាសតាមករណីនីមួយៗ។

<u>មាត្រា២១</u>៖ នៅរាល់ពេលដែលទទួលឱ្យធ្វើការ ឬបញ្ឈប់កម្មករនិយោជិកណាម្នាក់ និយោជកត្រូវធ្វើសេចក្តីប្រកាសជូនដំណឹង ទៅក្រសួងទទួលបន្ទុកវិស័យការងារ។ សេចក្តីប្រកាសជូនដំណឹងនេះត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលដប់ប្រាំថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលឱ្យធ្វើការ ឬបញ្ឈប់ឱ្យធ្វើការ។

<u>មាត្រា២២</u>៖ និយោជកនៃសហគ្រាស ឬគ្រឹះស្ថានដែលមានចែងក្នុងមាត្រា១៧ ខាងលើនេះ ហើយដែលមានកម្មករនិយោជិក យ៉ាងតិចប្រាំបីនាក់ត្រូវតែរៀបចំឱ្យមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសមួយជាដរាប។

<u>មាត្រា៣២</u>៖ ជនដែលមានសញ្ជាតិខ្មែរ ធ្វើការយកឈ្នួលពីនិយោជកណាមួយត្រូវតែមានសៀវភៅការងារ។ ជនណាក៏ដោយ មិនអាចប្រើកម្មករនិយោជិក ដែលមិនប្រតិបត្តិតាមបទបញ្ញត្ត នៃកថាខ័ណ្ឌខាងលើនេះបានទេ។

<u>មាត្រា៣៩</u>៖ និយោជកដែលមានរៀបរាប់ក្នុងមាត្រា១៧ខាងលើ ត្រូវប្រកាន់ដោយទៀងទាត់ដរាបនូវសៀវភៅបើកប្រាក់មួយ ដែលមានគម្រូ និងកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។ មុននឹងយកទៅប្រើសៀវភៅបើកប្រាក់ ត្រូវមានចុះលេខគ្រប់ទំព័រ និងចុះហត្ថលេខាសង្ខេបដោយអធិការការងារ។ សៀវភៅបើកប្រាក់នេះត្រូវទុកនៅ ក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស ដើម្បីនឹងបានងាយស្រួលក្នុងការត្រួតពិនិត្យ។ កាលណាប្រើសៀវភៅ នេះទំព័រទាំងអស់ និយោជកត្រូវទុកឱ្យគង់ក្នុងរយៈពេល៣ឆ្នាំ។ អធិការការងារអាចទាមរកសៀវភៅនេះនៅគ្រប់ពេលវេលា។

<u>មាត្រា៤១</u>៖ សហគ្រាសណាដែលចង់ធ្វើសៀវភៅបើកប្រាក់តាមរបៀបផ្សេងពីនេះ ប៉ុន្តែមានការចុះព័ត៌មាន និងបែបត្រួតពិនិត្យដូចគ្នា នោះអាចធ្វើពាក្យសុំទៅអធិការដ្ឋានការងារបាន។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា៦៨៖</u> កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករ និយោជិក និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។

<u>មាត្រា៣៣៧៖</u> ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីជាគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថេរវេលាធ្វើការពេញលេញនៃកម្មករនិយោជិកទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ។

<u>មាត្រា៣៧២៖</u> និយោជក និងនាយកគ្រឹះស្ថានដែលមានប្រើកម្មករជាក្មេង ឬកូនជាងអាយុតិចជាង ១៨ឆ្នាំ ឬស្ត្រីឱ្យធ្វើការក្នុងនោះត្រូវមើលឱ្យមានកិរិយាមារយាទល្អ ហើយនិងរក្សាការសមរម្យចំពោះសាធារណៈជនផង។ ត្រូវហាមឃាត់យ៉ាងតឹងរឹងចំពោះការរំលោភខាងផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់។

<u>មាត្រា៨២៖</u> ក្នុងសហគ្រាសទាំងអស់ដែលមានរាប់ក្នុងមាត្រា១ នៃច្បាប់នេះ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សម្រាកកៅសិបថ្ងៃដើម្បីសម្រាលកូន។ ក្រោយពីឈប់សម្រាលកូនមកក្នុងរយៈពេលពីរខែ ដែលបានចូលធ្វើការត្រូវឱ្យស្ត្រីនោះធ្វើការងារណាស្រាលៗ។ ត្រូវហាមឃាត់មិនឱ្យនិយោជកបញ្ឈប់ស្ត្រីសម្រាលកូននៅពេលឈប់ឆ្លងទន្លេ ឬនៅថ្ងៃណា មួយក្នុងពេលសម្រាលកូននេះ ទោះដោយវិធីឱ្យដំណឹងមុនក៏ដោយ។

<u>មាត្រា២២៩៖</u> គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវរក្សាឱ្យបានស្អាត ហើយបង្ហាញថាមានលក្ខខណ្ឌអនាម័យ និងសភាពសុខសប្បាយជានិច្ច ឬជាទូទៅត្រូវឱ្យមានលក្ខខណ្ឌការងារចាំបាច់សម្រាប់សុខភាពរបស់កម្មករនិយោជិក។

<u>មាត្រា២៨៨៖</u> ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលដែលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិក ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករ និយោជិកក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ។ ម៉្យាងវិញទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែល ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករ និយោជិកក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានទៅកន្លែងផ្សេង ជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតំរូវឱ្យទៅ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា២៨៣៖</u> ក្នុងករណីដែលមានគ្រោះថ្នាក់ដល់ស្លាប់ ឬគ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពពលកម្ម ជាអចិន្ត្រៃយ៍ ប្រាក់បំណាច់ត្រូវបើកឱ្យជនរងគ្រោះ ឬអ្នកសិទ្ធវន្តជាធនលាភ។ ត្រូវឱ្យប្រាក់បំណាច់បន្ថែមដល់អ្នករងគ្រោះណា ដែលតម្រូវឱ្យមានមនុស្សដទៃម្នាក់នៅថែទាំខ្លួនជានិច្ច។

<u>មាត្រា២៨៤៖</u> អ្នករងគ្រោះថ្នាក់ការងារត្រូវមានសិទ្ធិទទួលការពិនិត្យជម្ងឺ (ការផ្តល់ជាវត្ថុ ការព្យាបាលជម្ងឺ និងការផ្តល់ថ្នាំព្រមទាំងកន្លែងសម្រាកព្យាបាលជាដើម) និងការព្យាបាលខាងវះកាត់ និងផ្តល់បន្ថែមវត្ថុណាដែលចាំបាច់បន្ទាប់ពីគ្រោះថ្នាក់ទាំងនោះ។

<u>មាត្រា៣៨៩៖</u> អ្នកប្រព្រឹត្តល្មើស នឹងបទបញ្ញត្តនៃមាត្រាទាំងឡាយដូចមានចែងក្នុងជំពូក១៦ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬក៏ត្រូវទទួលទោសទាំងពីរ។ ការពិន័យជាប្រាក់ត្រូវដាក់បង្ខំដោយអធិការការងារ ឬអភិបាលការងារ។

២.៨ ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់ស្តីពីការវិនិយោគនៅកម្ពុជាត្រូវអនុម័តដោយសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៥ ខែសីហាឆ្នាំ១៩៩៤ ដែលមានខ្លឹមសារសំខាន់ៗដូចតទៅ៖

<u>មាត្រា៦៖</u>

យោងតាមរដ្ឋធម្មនុញ្ញនៃកម្ពុជា និងច្បាប់ពាក់ព័ន្ធ ទៅនឹងបញ្ញត្ត ដែលទាក់ទងទៅនឹងម្ចាស់កម្មសិទ្ធិ និងការប្រើប្រាស់ដីគឺ៖

- អ្នកវិនិយោគទុនសិទ្ធិកាន់កាប់ដីហើយប្រើប្រាស់ ក្នុងគោលបំណងនឹងអនុវត្តគម្រោងវិនិយោគ នៅលើដីកម្មសិទ្ធិរបស់ខ្លួន ត្រូវតែជាជនខ្មែរ និងមានសញ្ជាតិខ្មែរ ឬក្រុមហ៊ុនដែលបង្កើតដោយជនជាតិខ្មែរ។
- វិនិយោគិនទាំងអស់រួមទាំងត្រូវបានផ្តល់សិទ្ធិក្នុងការប្រើប្រាស់ដី រួមទាំងដីសម្បទាន ដែលកិច្ចសន្យារយៈពេលវែងមិនកំណត់ និងកិច្ចសន្យាកំណត់រយៈពេលខ្លី អាចធ្វើកិច្ចសន្យាថ្មីឡើងវិញបាន ដោយយោងទៅតាមប្រការទាំងឡាយដែលមានចែងក្នុងច្បាប់ភូមិបាល។
- វិនិយោគិនមានសិទ្ធិកាន់កាប់ និងធ្វើកិច្ចសន្យាៈផ្ទេរទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមាននៅលើដីសម្រាប់គម្រោងអភិវឌ្ឍន៍ ក្នុងរយៈពេលមិនយូរជាងការកំណត់ដែលនៅក្នុងកិច្ចសន្យានៃសម្បទានកម្មដី ឬក៏កិច្ចព្រមព្រៀងជួលដីទាំងឡាយដែលស្របទៅនឹងច្បាប់។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- វិនិយោគិនមិនអាចផ្ទេរ ឬធ្វើកិច្ចសន្យាចំពោះដីសម្បទាន នៅពេលដែលមិនទាន់មានដំណើរវិនិយោគ។

<u>មាត្រា៧៧៖</u>

រាល់វិនិយោគិនទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចជួលកម្មករដែលមានសញ្ជាតិខ្មែរ និងបរទេសបាន ដោយត្រូវអនុវត្ត និងគោរពតាមច្បាប់ការងារ និងច្បាប់អន្តោប្រវេស។

<u>មាត្រា៧៨៖</u>

វិនិយោគិនទាំងអស់ អាចជួលនិយោជិកបរទេសក្នុងករណីដូចខាងក្រោម៖

- អ្នកដែលមានជំនាញ និងសម្បាចំណេះដឹង ដែលជនជាតិខ្មែរគ្មាន។ នៅក្នុងករណីជួលកម្មករ ឬបុគ្គលិកបរទេសនេះដែរ បុគ្គលិកបរទេសទាំងនោះត្រូវមានថតចម្លងឯកសារសំខាន់ដូចជាលិខិតឆ្លងដែន សញ្ជាបត្រ ឬវិញ្ញាប័នបត្របញ្ជាក់ការសិក្សា ប្រវត្តិរូប ត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។
- ត្រូវភ្ជាប់លិខិតស្នាមស្រាប់ការជួលពលករបរទេស។ វិនិយោគិនត្រូវសុំសេចក្តីសម្រេច និងសេចក្តីអនុញ្ញាតពីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បា។
- មុនពេលបម្រើការឱ្យវិនិយោគិន និយោគជិកបរទេសទាំងអស់ ត្រូវបានអនុញ្ញាតឱ្យបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្រមតាមសម្រេចដោយក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បា។

វិនិយោគិតត្រូវអនុវត្តកាតព្វកិច្ចដូចខាងក្រោម៖

- ផ្តល់ការបណ្តុះបណ្តាលជំនាញគ្រប់គ្រាន់និងច្បាស់លាស់ដល់និយោគជិកកម្ពុជា
  - តម្លើងដំណែងដល់និយោគជិកកម្ពុជាឱ្យមានហានៈខ្ពស់ទៅតាមពេលវេលា។

<u>មាត្រា៧៩៖</u>

និយោគជិកបរទេស ត្រូវបានអនុញ្ញាតឱ្យផ្ញើប្រាក់ចំណូល និងប្រាក់ខែ ដែលខ្លួនរកបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រៅប្រទេសបន្ទាប់ពីការបង់ពន្ធសមស្របរួចរាល់ត្រូវផ្ញើរត្រូវជារួបរួយប័នអន្តរជាតិតាមរយៈប្រព័ន្ធនៃធនាគារ។

<u>មាត្រា២០៖</u>

លើកលែងតែដីដែលពាក់ព័ន្ធនឹងជម្លោះ ជម្លោះពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគ ដែលទាក់ទិនទៅនឹងសិទ្ធិ និងកាតព្វកិច្ច ដែលធ្វើឡើងដោយច្បាប់ ត្រូវដោះស្រាយដោយមានលក្ខណៈអធ្យាស្រ័យល្អនឹងគ្នា តាមរយៈការពិគ្រោះរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិនិយោគិន និងអ្នកពាក់ព័ន្ធនឹងជម្លោះ។

ប្រសិនបើភាគីទាំងសងខាងមិនអាចដោះស្រាយតាមអធ្យាស្រ័យក្នុងរយៈពេល២ខែ គិតចាប់តាំងពីថ្ងៃទី១នៃសរសេរពាក្យស្នើសុំឱ្យមានការពិគ្រោះយោបល់ដោះស្រាយ ភាគីណាមួយនៃជម្លោះអាច៖

- អាចលើកយកជម្លោះឱ្យក្រុមប្រឹក្សាដោះស្រាយ។
- សម្រេចដោយបណ្តុះត្តិនិច្ឆ័យក្នុង ឬនៅក្រៅប្រទេសកម្ពុជាដោយមានការយល់ព្រមពីភាគីសងខាង។
- សម្រេចដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា២១៖</u>

ប្រសិនបើវិនិយោគិនមានបំណងចង់បញ្ចប់សកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ដំណឹងដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈទម្រង់បែបបទ ឬលិខិតសរសេរដោយដៃ ព្រមទាំងបញ្ជាក់ពីហេតុផលនៃការសម្រេចចិត្ត ដោយមានចុះហត្ថលេខាពីអ្នកវិនិយោគ ឬមេធាវី។

<u>មាត្រា២២៖</u>

ប្រសិនបើអ្នកវិនិយោគចង់បញ្ឈប់សកម្មភាពនៃគម្រោងអភិវឌ្ឍន៍របស់ខ្លួន ដោយមិនស្រមតាមយុគនិវិធីនៃច្បាប់ វិនិយោគិនត្រូវផ្តល់ភស្តុតាងដល់ក្រុមប្រឹក្សា ដោយអះអាងថាគម្រោងអភិវឌ្ឍន៍បានដោះស្រាយបំណុលរបស់ខ្លួន ព្រមទាំងពន្ធដារដែលត្រូវបង់ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុនពេល មុនពេលដែលវិនិយោគិនត្រូវបានអនុញ្ញាតឱ្យឈប់សកម្មភាពវិនិយោគជាផ្លូវការ ដោយស្របតាមច្បាប់ពាណិជ្ជកម្មជាធរមាន។

<u>មាត្រា២៣៖</u>

គម្រោងវិនិយោគត្រូវបានបញ្ឈប់ភ្លាម តាមរយៈផ្លូវច្បាប់ ឬមិនមែនផ្លូវច្បាប់ អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅបរទេស ឬក៏ទុកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងករណីដែល គម្រោងវិនិយោគត្រូវប្រើប្រាស់ម៉ាស៊ីន ឬឧបករណ៍ ដែលនាំចូលដោយ

មិនមានការបង់ពន្ធសម្រាប់រយៈពេល៥ឆ្នាំ គម្រោងអភិវឌ្ឍន៍ត្រូវមានភារកិច្ចបង់ពន្ធនូវឧបករណ៍នឹងម៉ាស៊ីនទាំងនោះ ដោយយោងទៅតាមអនុក្រឹត្យដែលបានកំណត់។

<u>មាត្រា២៤៖</u>

វិនិយោគិតទាំងឡាយណា ដែលស្ថិតនៅក្រោមក្របខ័ណ្ឌនៃច្បាប់ស្តីពីការវិនិយោគដែលប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម លេខ០៣/NS/៩៤ ចុះនៅថ្ងៃទី៥ ខែសីហា ឆ្នាំ ១៩៩៤ និងអនុក្រឹត្យពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់ទុកថាគម្រោងវិនិយោគស្របច្បាប់ដូចដែលបានចែងជាធរមាននៅក្នុងច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធផ្សេងទៀត។

គម្រោងវិនិយោគត្រូវចុះឈ្មោះបង់ពន្ធចំនួន៩ភាគរយ នៃអត្រាប្រាក់ចំណេញរបស់ខ្លួនមុនពេលប្រកាសឱ្យប្រើប្រាស់ច្បាស់នេះ និងបានឱ្យចាប់ផ្តើមសកម្មភាពនៃវិនិយោគ និងត្រូវបានបង់ពន្ធចំនួនអត្រា៩ភាគរយ សម្រាប់រយៈពេល៥ឆ្នាំ ដោយចាប់ផ្តើមពីបង់ពន្ធដំបូង បន្ទាប់ពីការប្រកាសឱ្យប្រើប្រាស់នៃច្បាប់នេះ។ វិនិយោគិន ត្រូវផ្តល់ពន្ធជារៀងរាល់ឆ្នាំ បន្ទាប់ពីការប្រកាសឱ្យប្រើប្រាស់ច្បាប់នេះ ជាអជ្ញាប័ណនៃកតាព្វកិច្ចពេញចិត្ត ដែលត្រូវបានកំណត់ដោយអនុក្រឹត្យដូចដែលបានចែងក្នុងកថាខណ្ឌទី២នៃមាត្រាទី១៨។

គម្រោងវិនិយោគបានរួចផុតពីការបង់ពន្ធ មុនពេលការប្រកាសឱ្យប្រើប្រាស់នៃច្បាប់ ដោយមានការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា ហើយអាចបន្តរួចផុតពីការបង់ពន្ធអាស្រ័យទៅលើការចុះឆ្នាំសារពើភណ្ឌ បន្ទាប់ពីការលិខិតប្រកាសឱ្យប្រើប្រាស់នៃច្បាប់នេះ ចំពោះមុខរដ្ឋ ដែលលក្ខខណ្ឌទាំងឡាយដែលបានបញ្ជាក់ដោយអនុក្រឹត្យដែលបានចែងក្នុងកថាខណ្ឌទី២នៃមាត្រាទី១៨។

២.៩ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣។

<u>មាត្រា១៖</u>

ច្បាប់នេះមានគោលដៅជម្រុញ ឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់អំពី៖

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក

#322F, St.271Z, Sk.Tork Thla, Toulkok Khan, Phnom Penh
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍធនធានទឹកប្រកបដោយនិរន្តភាព។

<u>មាត្រា២៖</u>

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា៖

- ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស។
- ធនធានទឹកគឺទឹកសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងដងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក
- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មគួចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែង មួយទៅកន្លែងមួយទៀត។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ។
- ទន្លអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ។
- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹក នៅក្នុងទន្លេ ស្ទឹង ព្រែក អូរ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀត ដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះ។
- ឆ្នេរសមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្តានជម្រាល និងលិចទឹកម្តងម្កាល
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាតទឹកដែលគ្របដណ្តប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គីសនី ការបម្រើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារាទឹកអប្បរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្សជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្ខៀរ ទំនប់បញ្ចាល់ទឹក ទំនប់ទឹកការពារទឹកជំនន់ ប្រឡាយដោះទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកតូចធំ ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គីសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្ខែរទឹក រក្សាទឹកទុក នាំទឹកយកទៅប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ដីលិចទឹកការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក។

- អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យបុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។
- បុគ្គល គឺរូបវន្តបុគ្គល ឬនីតិបុគ្គលទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

<u>មាត្រា៣</u>៖ ទឹក និងធនធានទឹកជាសម្បត្តិរបស់រដ្ឋ។

<u>មាត្រា១១</u>៖

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណឡើយ។

<u>មាត្រា១២</u>៖

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្មលើសពីកម្រិតដែលមានចែងក្នុងមាត្រា១១ និងសំណង់ការពារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំ ជាអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ មិនមានចែងក្នុងអនុក្រឹត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរ សមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំ អាជ្ញាប័ណ្ណទឹក។ បែបបទបេចក្ខទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលម្អិតនៅក្នុងអនុក្រឹត្យ។ ការលប់ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិតម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។ ការសាងសង់ ស្ពានតូចធំ កាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អាគារតូចធំលើច្រាំង និងឆ្នេរទន្លេតម្រូវឱ្យមានការឯកភាពផ្តែកបច្ចេកទេសជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។ ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតនិងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ។

<u>មាត្រា១៤</u>៖

មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់ សំណង់ការពារទឹកដែលបុគ្គលនោះស្នើឡើង។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>មាត្រា២២៖</u>

រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹក សំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

<u>មាត្រា២៣៖</u>

ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល៖

- ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី។
- ទឹកលើទីជម្រាលដែលកំពុងរងការគម្រាមកំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាជន។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនិមួយៗដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

<u>មាត្រា៣២៖</u>

រាល់វិវាទ ដែលពាក់ព័ន្ធនឹងការបង្កើត និងដំណើការសេវាក្នុងការប្រើប្រាស់ទឹកត្រូវ សម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

<u>មាត្រា៣៤៖</u>

រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬការតម្លើងឧករណ៍ទំនើបដែលជួយកាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹកដើម្បីឱ្យការប្រើប្រាស់ទឹកមានប្រសិទ្ធភាពខ្ពស់។ លក្ខណៈវិនិច្ឆ័យ និងបែបបទសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

២.១០ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

អនុក្រឹត្យលេខ ៧២អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

<u>មាត្រា១៖</u>

អនុក្រឹត្យនេះមានគោលបំណង៖

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរដ្ឋាភិបាលសម្រេច។
- កំណត់ប្រភេទ និងទំហំនៃគម្រោងសកម្មភាព ដែលបានស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

<u>មាត្រា២៖</u>

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះគម្រោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចម្រុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋជាក្រសួង-ស្ថាប័នរដ្ឋ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែឡសម្រេចដោយរាជរដ្ឋាភិបាល។

<u>មាត្រា៣៖</u>

ក្រសួងបរិស្ថានមានភារៈកិច្ច៖

ក. ពិនិត្យ និងវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

ខ. តាមដាន ឃ្លាំមើល និងចាត់វិធានការឱ្យម្ចាស់គម្រោងប្រតិបត្តិតាម ដែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងក្នុងរបាយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច។